ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

លេខ: ៣០៤៥ មស.ទប

ជម្រាបជូន
ឯកឧត្តម លោកស្រី លោកប្រធាន គ្រប់អង្គភាព

**កម្មវត្ថុ** ៖ ករណីត្រួតពិនិត្យ និងពង្រឹងវត្តមានមន្ត្រីក្នុងអង្គភាព។

តបតាមកម្មវត្ថុខាងលើ សូមឯកឧត្តម លោកស្រី លោកប្រធាន គ្រប់អង្គភាពជ្រាបថា ៖ ក្នុងគោលបំណងចូលរួមយ៉ាងសកម្មក្នុងកំណែទម្រង់ស៊ីជម្រៅនៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា ក្រសួងមុខងារសាធារណៈសូមឲ្យឯកឧត្តម លោកស្រី លោកប្រធាន គ្រប់អង្គភាពទាំងអស់ ត្រូវអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់ ដូចខាងក្រោម ៖

១- ត្រួតពិនិត្យ និងពង្រឹងវត្តមានមន្ត្រីក្នុងអង្គភាពរបស់ខ្លួនឲ្យបានហ្មត់ចត់។

២- ប្រធានការិយាល័យ និងប្រធានមន្ទីរ ត្រូវទទួលខុសត្រូវផ្ទាល់ ចំពោះមន្ត្រីក្រោមឱវាទរបស់ខ្លួនដែលមិនបានមកធ្វើការទៀងទាត់ ឬអវត្តមានគ្មានមូលហេតុ ត្រូវរាយការណ៍មកប្រធានអង្គភាពសាមី ដើម្បីស្នើសុំមកក្រសួងចាត់វិធានការទៅតាមផ្លូវច្បាប់។

៣-ប្រធានអង្គភាព ឬ មន្ត្រីណាម្នាក់ដែលបើកប្រាក់បៀវត្សមន្ត្រីដែលមិនមកធ្វើការ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។ ក្នុងករណីអង្គភាពប្រឆាំងអំពើពុករលួយរកឃើញ មន្ត្រីដែលពាក់ព័ន្ធត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ដោយខ្លួនបុគ្គលនោះផ្ទាល់។

សេចក្តីដូចបានជម្រាបជូនខាងលើសូម ឯកឧត្តម លោកស្រី លោកប្រធានគ្រប់អង្គភាពត្រូវអនុវត្តខ្លឹមសារខាងលើឲ្យមានប្រសិទ្ធភាព ក្នុងស្មារតីទទួលខុសត្រូវខ្ពស់។

សូមឯកឧត្តម លោកស្រី លោកប្រធាន គ្រប់អង្គភាព ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៤
ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ

អៀម សារុំ

**ចម្លងជូន៖**
- ថ្នាក់ដឹកនាំ
"ដើម្បីជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ

អាសយដ្ឋាន: (កែងផ្លូវម៉ៃដាលេខ២០០៤) ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ ទូរស័ព្ទ.ទូរសារ(៨៥៥) ២៣ ៨៦៦ ៥០១